


# ការផ្តោតទៅលើកូវីដ-១៩របស់គម្រោងពន្លកចំណេះ៖ គោលនយោបាយដែលគាំទ្រដោយទិន្នន័យសម្រាប់ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច សង្គម និងសុខាភិបាលនៅកម្ពុជា

វិបត្តិដែលបង្កឡើងដោយជំងឺកូវីដ-១៩ បានធ្វើឱ្យការតាក់តែងគោលនយោបាយសាធារណៈ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល កាន់តែមានសារៈសំខាន់ជាងមុន។ **ទិន្នន័យ ភស្តុតាង និងការវិភាគទាន់ពេលវេលា** មានសារៈសំខាន់ណាស់នៅក្នុងស្ថានភាពបែបនេះ។ ទិន្នន័យ ភស្តុតាង និងការវិភាគទាំងនោះ តម្រូវ/បង្កលក្ខណៈ"ឱ្យអ្នកតាក់តែងគោលនយោបាយ និងដៃគូអភិវឌ្ឍន៍អាចសម្រេចចិត្ត និងទទួលបានលទ្ធផលកាន់តែប្រសើរលើផ្នែកសន្តិសុខ សុខាភិបាល ស្ថិរភាពនិងបរិយាប័ន្នសង្គម និងភាពធន់ផ្នែកសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញឆន្ទៈក្នុងការប្រើប្រាស់ដំណោះស្រាយដែលគាំទ្រដោយទិន្នន័យក្នុងអំឡុងពេលមានជំងឺរាតត្បាតនេះ។ វាជានិន្នាការមួយដែលគម្រោង ពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាសម្រាប់ការអភិវឌ្ឍនៅកម្ពុជា មានបំណងផ្តល់ការគាំទ្រ។

**ពន្លកចំណេះ** ជាកម្មវិធីរយៈពេល៣ឆ្នាំ (២០១៩ - ២០២២) ដែលគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។ កម្មវិធីនេះមានគោលបំណងពង្រឹងសមត្ថភាពស្ថាប័នក្នុងវិស័យស្រាវជ្រាវរួមទាំងស្ថាប័នស្រាវជ្រាវឯករាជ្យដើម្បីធ្វើការស្រាវជ្រាវដែលមានគុណភាពសម្រាប់គាំទ្រដល់ការវិភាគ និងការពិភាក្សាគោលនយោបាយសាធារណៈនៅកម្ពុជា។ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩គម្រោង**ពន្លកចំណេះ**បានចាត់វិធានការភ្លាមៗដោយធ្វើការកែតម្រូវសកម្មភាពបច្ចុប្បន្នរបស់ខ្លួនដើម្បីឆ្លើយតបឱ្យទាន់ពេលវេលាទៅនឹងស្ថានភាពដែលកំពុងតែវិវត្តយ៉ាងឆាប់រហ័ស។

ការផ្តោតទៅលើកូវីដ-១៩របស់**គម្រោងពន្លកចំណេះ** ឆ្លើយតបដោយផ្ទាល់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្ររបស់អូស្ត្រាលីដែលមានឈ្មោះថា ភាពជាដៃគូសម្រាប់ការស្តារឡើងវិញ (Partnership for Recovery Strategy)។ យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររបស់ជំងឺកូវីដ-១៩ នៅក្នុងតំបន់ក្បែរខាងនៃប្រទេសអូស្ត្រាលី ដូចជាតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ជាពិសេសប្រទេសនៅប្រជុំកោះប៉ាស៊ីហ្វិក ទីម័រខាងកើត និងអាស៊ីអាគ្នេយ៍។ វិធីសាស្ត្រដែលប្រទេសជិតខាងទាំងនេះប្រើប្រាស់ដើម្បីងើបចេញពីវិបត្តិជំងឺកូវីដ នឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់បរិបទសេដ្ឋកិច្ច និងយុទ្ធសាស្ត្ររបស់អូស្ត្រាលីក្នុងរយៈពេលជាច្រើនទសវត្សរ៍ទៅមុខ។ នៅក្នុងបរិបទនេះប្រទេសអូស្ត្រាលីប្តេជ្ញាសហការដោះស្រាយវិបត្តិនេះជាមួយកម្ពុជាដោយអូស្ត្រាលីបានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួនយ៉ាងលឿនដើម្បីគាំទ្រកម្ពុជារួមមានការផ្តោតទៅលើកម្មវិធីអភិវឌ្ឍន៍ដែលមានស្រាប់ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់របស់កូវីដ-១៩ ទៅលើផ្នែកសុខាភិបាល ស្ថិរភាព បរិយាប័ន្ន និងសេដ្ឋកិច្ច។

## គំនិតផ្តួចផ្តើម

គំនិតផ្តួចផ្តើមជាក់លាក់របស់គម្រោង**ពន្លកចំណេះ**ដែលគាំទ្រដល់ការស្តារឡើងវិញក្រោយជំងឺកូវីដ-១៩នៅប្រទេសកម្ពុជារួមមានៈ

### *ព័ត៌មាននៅលើប្រព័ន្ធអនឡាញស្តីពី ការឆ្លើយតបទៅនឹងកូវីដ-១៩នៅកម្ពុជា*

ដោយប្រើប្រាស់យន្តការដែលមានស្រាប់ដែលមានឈ្មោះថា" គំនិតផ្តួចផ្តើមបញ្ជីគោលនយោបាយ" គម្រោងបានបង្កើតទំព័រថ្មីមួយអំពីការឆ្លើយតបទៅនឹងកូវីដ-១៩នៅកម្ពុជាដែលទំព័រនេះផ្តល់ព័ត៌មានទៅដល់សាធារណៈជនពីវិធានការរបស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយការរីករាតត្បាតកូវីដ- ១ ៩ ។លោកអ្នកអាចចូលទៅកាន់ទំព័រថ្មីនេះតាមរយៈអាសយដ្ឋាន www.policypulse.org/ponlok-chomnes/covid19/។

## គាំទ្រដល់ការវិភាគរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ពីផលប៉ះពាល់នៃកូវីដ-១៩ ទៅលើធនធានមនុស្ស និងអនុសាសន៍សម្រាប់អ្នកតាក់តែងគោលនយោបាយលើវិស័យការងារ និងអប់រំ

វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI)កំពុងស្រាវជ្រាវលើប្រធានបទស្ដីពី"ការទទួលយកដោយបង្ខំនូវបច្ចេកវិទ្យាអប់រំក្នុងអំឡុងពេលជំងឺកូវីដ-១៩៖ករណីសិក្សាទៅលើស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សាក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍ"។ការស្រាវជ្រាវនេះមានគោលបំណងស្វែងយល់ពី១)តើវិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈ សាកលវិទ្យាល័យ ព្រមទាំងនិស្សិតបានត្រៀមខ្លួនត្រឹមកម្រិតណាដើម្បីប្ដូរទៅបង្រៀននិងរៀនតាមប្រព័ន្ធអ៊ីនធឺណិត?២)កត្តាកំណត់នៃការប្រើប្រាស់បច្ចេកវិទ្យាអប់រំនិងការរៀនសូត្រតាមប្រព័ន្ធអ៊ីនធឺណិតនិង៣)តើការប្រើប្រាស់និងការត្រៀមខ្លួនរវាងក្រុមដែលរងផលប៉ះពាល់ដែលកំពុងរស់នៅក្នុងតំបន់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលមានការរាតត្បាតជំងឺកូវីដមានភាពខុសគ្នាដែរឬទេ?លទ្ធផលនៃការស្រាវជ្រាវនេះនឹងផ្ដល់ជាមូលដ្ឋានទិន្នន័យលើបច្ចេកវិទ្យាអប់រំនិងការសិក្សាតាមអ៊ីនធឺណិតដើម្បីគាំទ្រដល់អ្នកតាក់តែងគោលនយោបាយនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា
ព្រមទាំងក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

## គាំទ្រដល់ការវិភាគរបស់មជ្ឈមណ្ឌលខេមរសិក្សា (CKS) ពីផលប៉ះពាល់នៃកូវីដ-១៩ ទៅលើបំណុលរបស់ក្រុមគ្រួសារក្រីក្រ

មជ្ឈមណ្ឌលខេមរសិក្សា(CKS)កំពុងធ្វើការស្រាវជ្រាវមួយក្រោមប្រធានបទ"កូវីដ-១៩បំណុលនិងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់គ្រួសារដែលមានចំណូលទាបនៅតាមជនបទនិងទីក្រុងក្នុងប្រទេសកម្ពុជា"។ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងយល់ឱ្យបានកាន់តែច្បាស់ពី(១)យុទ្ធសាស្ត្រនិងយន្តការដែលស្ថាប័នមីក្រូហិរញ្ញវត្ថុកំពុងអនុវត្តដើម្បីជួយសម្រួលដល់អ្នកខ្ចីប្រាក់ក្នុងពេលនិងក្រោយពេលមានវិបត្តិ(២)ការយល់ដឹងរបស់អ្នកខ្ចីប្រាក់ពីសិទ្ធិរបស់ខ្លួនព្រមទាំងវត្តមាននិងការប្រើប្រាស់យន្តការបណ្ដឹង។ការស្រាវជ្រាវនេះក៏នឹងបង្ហាញពីផលប៉ះពាល់នៃកូវីដ-១៩ទាំងផ្នែកសេដ្ឋកិច្ចនិងសង្គមទៅលើអ្នកខ្ចីប្រាក់ដោយស្វែងយល់ពីប្រភេទនៃយុទ្ធសាស្ត្រដែលពួកគេបានអនុវត្តកន្លងមក។លទ្ធផលនៃការស្រាវជ្រាវនេះនឹងត្រូវចែករំលែកជាមួយសាកលវិទ្យាល័យសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងក្រុមពាក់ព័ន្ធដទៃទៀត ។

## គាំទ្រដល់ការស្ទង់មតិ "អំពីការងារនៅក្នុងវិស័យទេសចរណ៍" និងអនុសាសន៍គោលនយោបាយដែលធ្វើឡើងដោយមជ្ឈមណ្ឌលសិក្សាគោលនយោបាយ(CPS) ដើម្បីគាំទ្រដល់គណៈកម្មាធិការជាតិសម្រាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មជ្ឈមណ្ឌលសិក្សាគោលនយោបាយ(CPS)កំពុងធ្វើ"ការស្ទង់មតិមួយស្ដីពីផលប៉ះពាល់នៃស្ថានភាពជំងឺកូវីដ-១៩ទៅលើអ្នកបម្រើការក្នុងវិស័យទេសចរណ៍នៅកម្ពុជា"។គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្ដែងនិងបញ្ហាប្រឈមនៃអ្នកបម្រើការក្នុងវិស័យទេសចរណ៍ដែលត្រូវបានផ្អាកការងារនិងស្វែងរកដំណោះស្រាយដែលអាចប្រើប្រាស់បានសម្រាប់រាជរដ្ឋាភិបាលនិងដៃគូដទៃទៀត។សំណួរសំខាន់នៃការស្រាវជ្រាវនេះគឺ"តើអ្នកបម្រើការក្នុងវិស័យទេសចរណ៍ដែលត្រូវបានបញ្ឈប់ពីការងារទទួលបានការគាំទ្រដោយផ្ទាល់និងដោយប្រយោលយ៉ាងដូចម្ដេច?"ការស្ទង់មតិនេះនឹងត្រូវធ្វើឡើងជាមួយនិយោជិកដែលត្រូវបានបញ្ឈប់ពីការងារចំនួន៥០០នាក់នៅរាជធានីភ្នំពេញខេត្តសៀមរាបនិងតាមតំបន់ឆ្នេរ។លទ្ធផលនៃការសិក្សានេះនឹងចូលរួមចំណែកក្នុងការផ្ដល់ធាតុចូលគោលនយោបាយសម្រាប់គណៈកម្មាធិការជាតិសម្រាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួងពាក់ព័ន្ធដទៃទៀត។

## គាំទ្រដល់ការស្ទង់មតិ និងសេចក្ដីសង្ខេបគោលនយោបាយដែលធ្វើឡើងដោយអង្គការវេទិកាអនាគត ស្ដីពីសហគ្រាសខ្នាតតូច និងកម្មករងាយរងគ្រោះ

ក្រុមហ៊ុនអង្គរស្រាវជ្រាវកម្ពុជា(ARC)និងអង្គការវេទិកាអនាគត(Future Forum)កំពុងអនុវត្តការស្រាវជ្រាវស្ដីពី"ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃកូវីដ-១៩ទៅលើកម្មករងាយរងគ្រោះនៅកម្ពុជា"។ការស្រាវជ្រាវនេះស្វែងរកផលប៉ះពាល់ជាក់ស្ដែងនៃកូវីដ-១៩ ទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ អាជីវករ និងម្ចាស់សហគ្រាសនានា។ការសិក្សានេះនឹងស្ទង់មតិពីកម្មករចំនួន១០០០នាក់និងគ្រួសារដែលបើកសហគ្រាសខ្នាតតូចព្រមទាំងកសិករតាមបណ្ដាខេត្ត និងក្រុងចំនួន៥ ។ អង្គការវេទិកាអនាគត នឹងរៀបចំការបកស្រាយគោលនយោបាយ អត្ថបទសង្ខេបនិងអត្ថបទអត្ថាធិប្បាយគោលនយោបាយដោយប្រើទិន្នន័យដែលប្រមូលបាន។ការសិក្សានេះមានគោលបំណងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយហានិភ័យនៃកូវីដ-១៩។របកគំហើញពីការស្រាវជ្រាវនេះក៏នឹងត្រូវបានបញ្ចូលទៅក្នុងការស្រាវជ្រាវថ្នាក់តំបន់ទាក់ទងទៅនឹងកម្មករងាយរងគ្រោះនៅតំបន់អាស៊ីអាគ្នេយ៍ផងដែរ។

## សម្រាប់ព័ត៌មានបន្ថែម


ponlokchomnes@asiafoundation.org

+៨៥៥ (២៣) ២១០ ៤៣១

https://policypulse.org/ponlok-chomnes/



គាំទ្រដោយ

Australian AID